# សង្ខេបសម្រាប់ គោលនយោបាយ

២០២៦ លេខ ០១ ពិសេស


# ការពង្រឹងអភិបាលកិច្ចទឹកនៅប្រទេសកម្ពុជា៖ ការឆ្លើយតបទៅនឹងហានិភ័យអាកាសធាតុ ការប្រែប្រួលផ្នែកជលសាស្ត្រ និងមុខងារស្ថាប័ន


សង្ខេបគោលនយោបាយនេះ គឺផ្អែកលើលទ្ធផលកិច្ចសន្ទនាគោលនយោបាយកម្រិតខ្ពស់ស្តីពីអភិបាលកិច្ចទឹកនៅព្រះរាជាណាចក្រកម្ពុជា។

របៀបយោងអត្ថបទនេះ៖
CDRI. 2026. *Strengthening Water Governance in Cambodia: Responding to Climate Risks, Altered Hydrology and Institutional Fragmentation*. Policy Brief 2026 No. 01 Special Issue. Phnom Penh: CDRI.

ISSN 3134-6286 (Print)
ISSN 3134-6294 (Online)
DOI: https://doi.org/10.64202/pb.01.2026.02



## សារសំខាន់ៗ

- អភិបាលកិច្ចទឹកល្អ ត្រូវមានតម្លាភាព គណនេយ្យភាព ការចូលរួម ការឆ្លើយតប និងការគោរពនីតិរដ្ឋ ដើម្បីធានាថា ទឹកត្រូវបានបែងចែកដោយយុត្តិធម៌ ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងត្រូវបានការពារសម្រាប់មនុស្សជំនាន់ក្រោយ តាមរយៈប្រសិទ្ធភាពស្ថាប័ន និងគោលនយោបាយ។
- សម្ពាធកាន់តែខ្លាំង បង្កឡើងដោយទឹកជំនន់ គ្រោះរាំងស្ងួត ការបំពុល ការប្រកួតប្រជែងតម្រូវការទឹកប្រើប្រាស់ និងការប្រែប្រួលអាកាសធាតុ កំពុងតែបង្កើនហានិភ័យ ដែលគំរាមកំហែងដល់វិស័យកសិកម្ម ការនេសាទ សុខភាពសាធារណៈ និងស្ថិរភាពសេដ្ឋកិច្ចទូទាំងប្រទេស។
- មុខងារក្រសួងពាក់ព័ន្ធមិនទាន់មានភាពស៊ីសង្វាក់គ្នា បណ្តាលឱ្យការសម្របសម្រួល និងការអនុវត្តច្បាប់មានភាពទន់ខ្សោយ ដែលទាមទារឱ្យមានក្របខ័ណ្ឌច្បាប់ដែលរឹងមាំ ការកំណត់តួនាទីស្ថាប័នច្បាស់លាស់ ការរៀបចំផែនការមានលក្ខណៈចម្រុះ និងសមត្ថភាព និងធនធានគ្រប់គ្រាន់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ការចូលរួមរួមដោយបរិយាបន្ន គឺមានសារៈសំខាន់ តាមរយៈការផ្តល់អំណាចដល់ស្ត្រី ក្រុមជនជាតិដើមភាគតិច កសិករ និងសហគមន៍មូលដ្ឋាន ក្នុងការគ្រប់គ្រងធនធានរួមគ្នា ការដោះស្រាយវិវាទ និងពង្រឹងគណនេយ្យភាព តាមវិធីសាស្ត្រដែលផ្អែកលើសហគមន៍។
- ការធ្វើសេចក្តីសម្រេចត្រូវមានមូលដ្ឋានទិន្នន័យ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយមានការគាំទ្រពីប្រព័ន្ធត្រួតពិនិត្យ ទិន្នន័យបើកចំហ ប្រព័ន្ធប្រកាសឱ្យដឹងមុន និងឧបករណ៍ឌីជីថលដែលសមស្របនឹងបរិបទ ដើម្បីបង្កើនតម្លាភាព និងភាពធន់។
- ចីរភាពហិរញ្ញប្បទាន ការចូលរួមពីវិស័យឯកជន និងកិច្ចសហប្រតិបត្តិការតំបន់ ជាពិសេសតាមរយៈ គណៈកម្មការទន្លេមេគង្គ គឺមានសារៈសំខាន់ណាស់ ក្នុងការកៀរគរធនធាន ពង្រីកសេវាកម្ម និងការគ្រប់គ្រងហានិភ័យទឹករួមគ្នា។


## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជា សម្បូរទៅដោយធនធានទឹកតាមរដូវកាល ដែលមានប្រភពពីទន្លេមេគង្គ បឹងទន្លេសាប និងទឹកក្រោមដី ប៉ុន្តែអសន្តិសុខទឹកកំពុងកើនឡើង ដោយសារភាពទន់ខ្សោយផ្នែកអភិបាលកិច្ច និងការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធ មិនមែនដោយសារកង្វះទឹកនោះទេ។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ក្រសួងធនធានទឹក និងឧតុនិយម និងវិទ្យាស្ថាន CDRI បានសហការរៀបចំកិច្ចសន្ទនាគោលនយោបាយកម្រិតខ្ពស់ ស្តីពីអភិបាលកិច្ចទឹកនៅព្រះរាជាណាចក្រកម្ពុជា ដោយមានការអញ្ជើញចូលរួមពីអង្គភាពរដ្ឋាភិបាល អ្នកស្រាវជ្រាវ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដើម្បីកំណត់មាគ៌ាឆ្ពោះទៅកាន់ការគ្រប់គ្រងទឹកដែលមានភាពធន់ និងប្រកបដោយបរិយាបន្ន។

អង្គពិភាក្សាបានលើកឡើងពីសម្ពាធកាន់តែខ្លាំង ពីការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍវារីអគ្គិសនី ការបាត់បង់ដីល្បាប់ ការធ្លាក់ចុះផលនេសាទ សម្ពាធពីបញ្ហាទឹកក្រោមដី និងការសម្របសម្រួលមុខងារស្ថាប័នមិនច្បាស់លាស់ ដែលគំរាមកំហែងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងប្រព័ន្ធអេកូឡូស៊ី។ អ្នកចូលរួមបានលើកឡើងពីកង្វល់ ទាក់ទងនឹងចីរភាពរបស់បឹងទន្លេសាប លំហូរទឹកទន្លេមេគង្គ និងការគ្រប់គ្រងទឹកក្រោមដីប្រកបដោយចីរភាព។ អ្នកចូលរួមបានស្នើឱ្យមានការ

ពង្រឹងក្របខ័ណ្ឌច្បាប់ឱ្យកាន់តែរឹងមាំ កែលម្អការសម្របសម្រួលស្ថាប័ន និងមានកិច្ចសហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់។ វិធានការទាំងនេះអាចអនុវត្តបាន តាមរយៈគណៈកម្មការទន្លេមេគង្គ (MRC) ព្រមទាំងការពង្រីកវេទិកាវិមជ្ឈការ ដែលមានការបែងចែកអំណាចទៅថ្នាក់ក្រោមជាតិ ដូចជា ក្រុមការងារបច្ចេកទេស (TWGs) និងការបន្តវិនិយោគលើវិស័យសេវាទឹកស្អាត និងអនាម័យ (WASH) និងការស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ។

## ២. ធនធានទឹកនៅប្រទេសកម្ពុជា និងបញ្ហាប្រឈម

នៅប្រទេសកម្ពុជា សន្តិសុខទឹក ត្រូវបានកំណត់ដោយប្រព័ន្ធភ្ជាប់គ្នារវាងទន្លេមេគង្គ បឹងទន្លេសាប និងប្រភពទឹកក្រោមដីនៅទូទាំងប្រទេស ដែលគាំទ្រដល់វិស័យកសិកម្ម ការនេសាទ ការផលិតថាមពល ការផ្គត់ផ្គង់ទឹកប្រើប្រាស់ និងជីវភាពជនបទ។ ជាពិសេស ទន្លេមេគង្គគាំទ្រដល់ផលិតកម្មស្រូវក្នុងតំបន់ប្រហែល ៥១% ផលនេសាទ ៥០% និងផលិតកម្មថាមពលក្នុងតំបន់ជាង ១០% ដែលបង្ហាញពីតួនាទីសំខាន់ផ្នែកសេដ្ឋកិច្ចនៃទន្លេមេគង្គ។ ទោះជាយ៉ាងណា ការកើនឡើងនៃគ្រោះរាំងស្ងួត និងទឹកជំនន់ ការបាត់បង់ដីល្បាប់ ការថយចុះលំហូរទឹកបញ្ច្រាសពីទន្លេមេគង្គទៅទន្លេសាប និងការពឹងផ្អែកខ្លាំងលើលំហូរទឹកឆ្លងព្រំដែនទាំងនេះ កំពុងបង្កអស្ថិរភាពដល់ប្រព័ន្ធទន្លេមេគង្គ។ ដីល្បាប់ដែលថយចុះពី ៥០% ទៅ ៧០% នៅតំបន់ខ្លះ បណ្តាលឱ្យដីបាត់បង់ជីជាតិ មានការបាក់ស្រុតច្រាំងទន្លេ និងធ្វើឱ្យប៉ះពាល់ដល់ជម្រកត្រី។

បឹងទន្លេសាប នៅតែជាតំបន់ស្នូលសម្រាប់ប្រព័ន្ធអេកូឡូស៊ី និងជាបេះដូងនៃសន្តិសុខស្បៀងអាហារកម្ពុជា។ ជាបឹងទឹកសាបធំបំផុតនៅអាស៊ីអាគ្នេយ៍ ទន្លេសាបផ្តល់ទិន្នផលត្រីប្រហែល ៥០ម៉ឺនតោនក្នុងមួយឆ្នាំ និងរួមចំណែកដល់ផលិតផលក្នុងស្រុកសរុប (ផសស) ប្រមាណ ១០%។ ទោះជាយ៉ាងណា ជីពចរទឹកជំនន់តាមរដូវកាលដែលមានរយៈពេលកាន់តែខ្លី និងខ្សោយ ការខូចខាតទីជម្រកធម្មជាតិ ការបំពុល និងការនេសាទហួសកម្រិត កំពុងធ្វើឱ្យបរិមាណត្រី និងផលិតភាពប្រព័ន្ធអេកូឡូស៊ីថយចុះ ដែលគំរាមកំហែងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរាប់លាននាក់ ដែលពឹងផ្អែកលើវិស័យនេសាទ និងកសិកម្មនៅតំបន់វាលទំនាបលិចទឹក។

ទឹកក្រោមដី កំពុងក្លាយជាប្រភពសុវត្ថិភាពដ៏សំខាន់នៅរដូវប្រាំង ដោយមានការប៉ាន់ប្រមាណថា ទឹកក្រោមដីមានបរិមាណ ១៧៦០០លានម៉ែត្រគូប និងមានអណ្តូងទឹកចំនួនជាង ៦១៧០០ នៅទូទាំងប្រទេស។ ទោះជាយ៉ាងណា មានការព្រួយបារម្ភអំពីចីរភាពទឹកក្រោមដី ដោយសារការបូមយកទឹកយ៉ាងលឿន ដែលភាគច្រើនដោយមិនមានការគ្រប់គ្រង ការធ្លាក់ចុះកម្រិតទឹកក្រោមដី ការជ្រៀតចូលទឹកប្រៃ និងការត្រួតពិនិត្យតាមដានមានកម្រិត។

ជារួម ឧបសគ្គចម្បងមិនមែនជាកង្វះធនធានទឹកនោះទេ ប៉ុន្តែគឺជាការបែងចែកមុខងារនៅក្នុងអភិបាលកិច្ចទឹក។ ដូច្នេះ ការពង្រឹងការគ្រប់គ្រងធនធានទឹកបែបចម្រុះ ប្រព័ន្ធទិន្នន័យរួម ការការពារប្រព័ន្ធអេកូឡូស៊ី ស្ថាប័នអភិបាលកិច្ចទឹកបែបវិមជ្ឈការ ការគ្រប់គ្រងទឹកក្រោមដី និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ មានសារៈសំខាន់ណាស់ សម្រាប់កសាងសន្តិសុខទឹកនៅប្រទេសកម្ពុជា ដែលធន់នឹងអាកាសធាតុ និងមានភាពសមធម៌។

## ៣. សកម្មភាពគន្លឹះសម្រាប់ការកែលម្អអភិបាលកិច្ចទឹក

កិច្ចសន្ទនាគោលនយោបាយកម្រិតខ្ពស់ ស្តីពីអភិបាលកិច្ចទឹកនៅប្រទេសកម្ពុជា បានកំណត់វិស័យសកម្មភាពគន្លឹះមួយចំនួនសម្រាប់ការកែលម្អអភិបាលកិច្ចទឹកនៅកម្ពុជា ដែលជាលទ្ធផលពីការធ្វើបទបង្ហាញដោយវាគ្មិនសំខាន់ៗ ការពិភាក្សាក្រុមជំនាញ និងការពិភាក្សាដោយបើកចំហ ព្រមទាំងវគ្គសំណួរ និងចម្លើយ។

### *៣.១ ការបែងចែកមុខងារស្ថាប័ន និងអភិបាលកិច្ច*

បញ្ហាទឹកនៅប្រទេសកម្ពុជា មិនមែនបណ្តាលមកពីកង្វះធនធានទឹកប៉ុណ្ណោះទេ ប៉ុន្តែវាបណ្តាលមកពីអភិបាលកិច្ចមិនស៊ីសង្វាក់គ្នា និងការសម្របសម្រួលស្ថាប័នមានភាពទន់ខ្សោយ។ ទោះបីមានលំហូរទឹកពីទន្លេមេគង្គ និងបឹងទន្លេសាបដ៏ច្រើនយ៉ាងណាក៏ដោយ ការទទួលខុសត្រូវដែលត្រួតស៊ីគ្នារវាងក្រសួងពាក់ព័ន្ធ បានធ្វើឱ្យការសម្របសម្រួល ការអនុវត្តច្បាប់ និងគណនេយ្យភាពចុះខ្សោយ ដែលបណ្តាលឱ្យមានការរៀបចំផែនការដាច់ដោយឡែកពីគ្នា ការវិនិយោគស្ទួនគ្នា និងសមត្ថភាពនៅមានកម្រិតក្នុងការគ្រប់គ្រងហានិភ័យអន្តរវិស័យ។ ថ្វីដ្បិតមានកំណែទម្រង់វិមជ្ឈការក៏ពិតមែន តែអំណាច ថវិកា និងសមត្ថភាពបច្ចេកទេសនៅតែប្រមូលផ្តុំនៅថ្នាក់លើជាអ្នកសម្រេច ដែលធ្វើឱ្យស្ថាប័នថ្នាក់មូលដ្ឋាន ខ្វះធនធានក្នុងការដោះស្រាយវិវាទ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

ដូច្នេះ ការកែទម្រង់គួរផ្តោតអាទិភាពលើ ការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ដោយមានការកំណត់ភារកិច្ចឱ្យបានច្បាស់លាស់ មានសុខដុមនីយកម្មច្បាប់ និងមានស្ថាប័នដឹកនាំសម្របសម្រួលមួយ ដើម្បីជំរុញឱ្យមានភាពស៊ីសង្វាក់គ្នាក្នុងការធ្វើផែនការអន្តរវិស័យ។ ផែនការគ្រប់គ្រងអាងទឹករួម ប្រព័ន្ធចែករំលែកទិន្នន័យ និងការប្រមូលផ្តុំធនធានហិរញ្ញវត្ថុរួម អាចជួយបង្កើនប្រសិទ្ធភាពអភិបាលកិច្ចទឹក ខណៈការផ្ទេរធនធានទៅថ្នាក់មូលដ្ឋាន និងការពង្រឹងការចូលរួម តម្លាភាព និងអនុលោមភាពតាមច្បាប់ នឹងជួយបង្កើនគណនេយ្យភាព និងកសាងប្រព័ន្ធអភិបាលកិច្ចទឹកមួយដែលមានភាពធន់ សមធម៌ និងភាពបត់បែននឹងការប្រែប្រួលអាកាសធាតុ។

### *៣.២ ការប្រែប្រួលអាកាសធាតុ និងអស្ថិរភាពផ្នែកជលសាស្ត្រ*

ការប្រែប្រួលអាកាសធាតុ កំពុងបង្កើនអស្ថិរភាពផ្នែកជលសាស្ត្រនៅទូទាំងប្រទេសកម្ពុជា និងអាងទន្លេមេគង្គ ដែលបង្កឱ្យមានគ្រោះរាំងស្ងួត និងជំនន់ទឹកភ្លៀងញឹកញាប់ជាងមុន

រូបភាពទី១៖ ធនធានទឹកទន្លេមេគង្គ បឹងទន្លេសាប និងទឹកក្រោមដីនៅប្រទេសកម្ពុជា




ប្រភព៖ ចងក្រងចេញពីបទបង្ហាញដោយវាគ្មិនមកពីគណៈកម្មការទន្លេមេគង្គ អាជ្ញាធរទន្លេសាប និងក្រសួងធនធានទឹក និងឧតុនិយម នៅក្នុង*កិច្ចសន្ទនាគោលនយោបាយកម្រិតខ្ពស់ស្តីពីអភិបាលកិច្ចទឹកនៅព្រះរាជាណាចក្រកម្ពុជា* ទីក្រុងភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥។

ហើយប៉ះពាល់ដល់វិស័យកសិកម្ម ការនេសាទ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ការចុះខ្សោយជីពចរតំបន់លិចទឹកនៃបឹងទន្លេសាប ដែលសម្គាល់បានដោយការថយចុះលំហូរទឹកបញ្ច្រាសពីទន្លេមេគង្គទៅទន្លេសាប និងរយៈពេលលិចទឹកខ្លីជាងមុន បានកម្រិតការផ្លាស់ទីរបស់ត្រី បំផ្លាញទីជម្រកធម្មជាតិ និងបន្ថយជីជាតិដី ដែលគំរាមកំហែងដល់សន្តិសុខស្បៀងអាហាររបស់សហគមន៍រស់នៅតំបន់វាលទំនាបលិចទឹក។

ស្ថានភាពអាក្រក់ទាំងនេះបង្ហាញថា ប្រព័ន្ធរៀបចំផែនការដែលរចនាឡើងសម្រាប់ស្ថានភាពមានស្ថិរភាព មិនអាចឆ្លើយតបទៅនឹងបញ្ហាទាំងនេះបានទេ។ ហេដ្ឋារចនាសម្ព័ន្ធ និងស្ថាប័ននានាកំពុងជួបការលំបាក ក្នុងការគ្រប់គ្រងភាពប្រែប្រួលដែលកើនឡើង បានបង្ហាញពីតម្រូវការបន្ទាន់នូវការគ្រប់គ្រងធនធានទឹកបែបចម្រុះ ហើយធន់នឹងការប្រែប្រួលអាកាសធាតុ និងផ្អែកលើប្រព័ន្ធអេកូឡូស៊ី តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលរវាងស្ថាប័នមានភាពល្អប្រសើរជាងមុន និងមានប្រព័ន្ធប្រកាសឱ្យដឹងមុន។

### *៣.៣ ការបាត់បង់ប្រព័ន្ធអេកូឡូស៊ី និងដីល្បាប់*

នៅទូទាំងតំបន់អាងទន្លេមេគង្គ ការថយចុះលំហូរដីល្បាប់ដែលភាគច្រើនបណ្តាលមកពី ទំនប់វារីអគ្គិសនីនៅខ្សែទឹកខាងលើទន្លេ និងការផ្លាស់ប្តូររបបទឹកជំនន់ កំពុងតែធ្វើឱ្យខូចប្រព័ន្ធអេកូឡូស៊ី និងធ្វើឱ្យផលិតភាពវិស័យកសិកម្មធ្លាក់ចុះ។ ការបាត់បង់ដីល្បាប់ បានធ្វើឱ្យជីជាតិដីធ្លាក់ចុះ បង្កើនសំណឹកដីកាន់តែរហ័ស និងធ្វើឱ្យតំបន់វាលទំនាបលិចទឹកកាន់តែតូចទៅៗ ដែលជាជម្រកមច្ឆជាតិដ៏សំខាន់ សម្រាប់ការនេសាទ និងកសិកម្ម។ ទន្ទឹមនឹងនេះ ការបំផ្លាញជម្រកធម្មជាតិ ការថយចុះតំបន់ព្រៃលិចទឹក និងការបំពុល បានបង្កផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីទឹកបន្ថែមទៀត។ ផលប៉ះពាល់ទាំងនេះ មានកាន់តែធ្ងន់ធ្ងរនៅបឹងទន្លេសាប ដោយសារការថយចុះលំហូរទឹកបញ្ច្រាសពីទន្លេមេគង្គទៅទន្លេសាប និងរយៈពេលលិចទឹកខ្លីជាងមុន កំពុងគំរាមកំហែងដល់ផលិតភាពរបស់បឹង និងបរិមាណនៃការនេសាទត្រីប្រមាណកន្លះលានតោនក្នុងមួយឆ្នាំ។

អ្នកចូលរួមកិច្ចសន្ទនាបានសង្កត់ធ្ងន់ថា ការធ្លាក់ចុះប្រព័ន្ធអេកូឡូស៊ី បង្កើនភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងសង្គមដោយផ្ទាល់។ ការថយចុះធនធានត្រី និងការធ្លាក់ចុះគុណភាពដី បានកាត់បន្ថយប្រាក់ចំណូល សន្តិសុខស្បៀងអាហារ និងភាពធន់របស់សហគមន៍នៅតំបន់វាលទំនាបលិចទឹក ដែលពឹងផ្អែកលើការនេសាទ និងការធ្វើស្រែចម្ការ។ ការដោះស្រាយហានិភ័យទាំងនេះ ត្រូវការការពារប្រព័ន្ធតំណភ្ជាប់លំហូរដីល្បាប់ ការស្តារទីជម្រកធម្មជាតិឡើងវិញ ការពង្រឹងប្រព័ន្ធតាមដាន និងការដាក់បញ្ចូលវិធានការការពារប្រព័ន្ធអេកូឡូស៊ី ទៅក្នុងការរៀបចំផែនការអាងទន្លេ និងការប្រតិបត្តិការទំនប់ ដើម្បីធ្វើឱ្យមានតុល្យភាពរវាងការអភិវឌ្ឍថាមពល និងជីវភាពរស់នៅប្រកបដោយចីរភាពរយៈពេលវែង។

### *៣.៤ បញ្ហាសម្ពាធលើទឹកក្រោមដី និងបញ្ហាកង្វះបទប្បញ្ញត្តិពាក់ព័ន្ធ*

ទឹកក្រោមដី កំពុងក្លាយជាប្រភពទឹកដ៏សំខាន់មួយសម្រាប់រដូវប្រាំងនៅប្រទេសកម្ពុជា ខណៈដែលលំហូរទឹកនៅលើដីពីទន្លេមេគង្គ និងបឹងទន្លេសាប កំពុងថយចុះ។ ប្រជាពលរដ្ឋជាច្រើនគ្រួសារ ពឹងផ្អែកលើអណ្តូងទឹកសម្រាប់ប្រើប្រាស់ក្នុងផ្ទះ ចំណែកកសិករពឹងផ្អែកលើទឹកក្រោមដី សម្រាប់ការស្រោចស្រពស្រែចម្ការ ប៉ុន្តែមានកំណើនការបូមយកទឹកឡើងយ៉ាងឆាប់រហ័ស គឺច្រើនលើសពីសមត្ថភាពដែលអាចគ្រប់គ្រង និងត្រួតពិនិត្យផ្នែកបច្ចេកទេសបាន។ ការត្រួតពិនិត្យតាមដាន នៅតែមានកម្រិតទាបអត្រាការបំពេញទឹកក្រោមដីឡើងវិញ មិនទាន់មានការយល់ដឹងបានច្បាស់ ហើយកង្វះទិន្នន័យ ក៏រារាំងដល់ការរៀបចំផែនការដែលមានចីរភាពផងដែរ។ ការគ្រប់គ្រងមានភាពទន់ខ្សោយ និងការផ្តល់អាជ្ញាប័ណ្ណមានកម្រិតតិចតួច បានបន្ថែមហានិភ័យក្នុងការទាញយកទឹកលើសកម្រិត។

នៅតំបន់ឆ្នេរ និងតំបន់ទំនាប ការថយចុះក្នុងការបំពេញទឹកក្រោមដីឡើងវិញ និងការកើនឡើងកម្រិតទឹកសមុទ្រ កំពុងបង្កើនទឹកប្រៃជ្រាបចូល និងហានិភ័យចំពោះគុណភាពទឹកដែលអាចនាំឱ្យកម្រិតទឹកក្រោមដីធ្លាក់ចុះ បង្កើនថ្លៃដើម និងបណ្តាលឱ្យមានការខ្វះខាតទឹកក្នុងរយៈពេលវែង។ ការពង្រឹងចីរភាពទឹកក្រោមដី ត្រូវការការពង្រីកប្រព័ន្ធតាមដាន បទប្បញ្ញត្តិច្បាស់លាស់ ការគ្រប់គ្រងលើការបូមទាញយកទឹក ឱ្យមានកម្រិតសមស្រប ការការពារតំបន់បំពេញទឹកក្រោមដីឡើងវិញ និងការដាក់បញ្ចូលការគ្រប់គ្រងទឹកក្រោមដីទៅក្នុងផែនការទឹកជាតិ ដើម្បីធានាថា ទឹកក្រោមដីនៅតែជាប្រភពសំខាន់ សម្រាប់បន្ធូរបន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

### *៣.៥ វិសមភាពសេវាទឹកស្អាត និងអនាម័យ (WASH)*

ការមានទឹកស្អាត និងអនាម័យប្រកបដោយសុវត្ថិភាព នៅតែមានវិសមភាពនៅទូទាំងប្រទេសកម្ពុជា ដោយខ្វះខាតខ្លាំងជាងគេនៅតំបន់ជនបទ តំបន់ដាច់ស្រយាល និងសហគមន៍បណ្តែតទឹកនៅជុំវិញបឹងទន្លេសាប និងវាលទំនាបទន្លេមេគង្គ។ ប្រជាពលរដ្ឋជាច្រើនគ្រួសារពឹងផ្អែកលើប្រភពទឹកតាមរដូវកាល ឬនៅតែប្រើប្រាស់ទឹកដែលមិនបានធ្វើប្រព្រឹត្តកម្ម ឬសម្អាតត្រឹមត្រូវ ហើយគ្មានអនាម័យគ្រប់គ្រាន់ ដូច្នេះវាបានបង្កើនភាពងាយរងគ្រោះដោយជំងឺកើតពីទឹក និងធ្វើឱ្យសុខភាព និងផលិតភាពធ្លាក់ចុះ។ ម្យ៉ាងវិញទៀត បម្រែបម្រួលអាកាសធាតុ ធ្វើឱ្យហានិភ័យទាំងនេះកាន់តែធ្ងន់ធ្ងរ ខណៈទឹកជំនន់ បានធ្វើឱ្យកខ្វក់ដល់ការផ្គត់ផ្គង់ទឹក និងគ្រោះរាំងស្ងួត បានធ្វើឱ្យការទទួលបានទឹកប្រើប្រាស់មានកម្រិត។

ស្ត្រី កុមារ និងក្រុមងាយរងគ្រោះ ទទួលរងផលប៉ះពាល់ខ្លាំងជាងគេពីហានិភ័យទាំងនេះ។ ដើម្បីដោះស្រាយវិសមភាពទាំងនេះ តម្រូវឱ្យមានការវិនិយោគមានគោលដៅលើហេដ្ឋារចនាសម្ព័ន្ធសេវាទឹកស្អាត និងអនាម័យ ដែលធន់នឹងអាកាសធាតុ ការកែ

លម្អការអប់រំអនាម័យ វិមជ្ឈការសេវាកម្ម និងការរួមបញ្ចូលសេវាទឹកស្អាត និងអនាម័យទៅក្នុងអភិបាលកិច្ចទឹក និងការធ្វើផែនការអាងទន្លេជាទូទៅ។

### ៣.៦ ទិន្នន័យ បច្ចេកវិទ្យា និងនវានុវត្តន៍

ទិន្នន័យ បច្ចេកវិទ្យា និងនវានុវត្តន៍ មានសារៈសំខាន់សម្រាប់អភិបាលកិច្ចទឹកដោយប្រសិទ្ធភាព ដែលអាចអនុញ្ញាតឱ្យមានការសម្រេចចិត្តដោយផ្អែកលើភស្តុតាង ជាជាងផ្អែកលើការឆ្លើយតបរបស់ស្ថាប័នរៀងៗខ្លួន។ ទិន្នន័យជលសាស្ត្រ ដីល្បាប់ ទឹកក្រោមដី គុណភាពទឹក និងអាកាសធាតុនៅទូទាំងអាងទន្លេមេគង្គ និងបឹងទន្លេសាប ជួយគាំទ្រដល់ការព្យាករ ការគ្រប់គ្រងធនធានដោយប្រសិទ្ធភាព និងការការពារប្រព័ន្ធអេកូឡូស៊ី។ លើសពីនេះ ឧបករណ៍ឌីជីថល និងការសង្កេតរបស់សហគមន៍ អាចបង្កើនតម្លាភាព និងការរៀបចំផែនការដែលអាចបត់បែនបាន។

ទោះបីជាយ៉ាងណា ប្រព័ន្ធព័ត៌មាននៅមានលក្ខណៈបែកខ្ញែក និងចែកចាយនៅក្នុងអង្គភាពមិនបានទូលំទូលាយ ដូច្នេះបានធ្វើឱ្យការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធចុះខ្សោយ។ ដើម្បីប្រែក្លាយភស្តុតាង ទៅជាការសម្រេចចិត្តដែលមានគណនេយ្យភាព និងការឆ្លើយតបដោយឡែកៗគ្នា ចាំបាច់ត្រូវមានកិច្ចសហការកាន់តែរឹងមាំ មូលដ្ឋានទិន្នន័យរួមបញ្ចូលគ្នា វេទិកាទិន្នន័យបើកចំហ និងភាពជាដៃគូរវាងវិទ្យាសាស្ត្រ និងគោលនយោបាយ។

### ៣.៧ វិធីសាស្ត្របែបវិមជ្ឈការ និងបរិយាបន្នបង្ហាញពីសក្តានុពល

គំនិតផ្តួចផ្តើមសាកល្បងនៅថ្នាក់ស្រុកជាច្រើន បានបង្ហាញថា វេទិកាពហុភាគីបែបវិមជ្ឈការ អាចធ្វើឱ្យប្រសើរឡើងនូវលទ្ធផលក្នុងអភិបាលកិច្ចទឹក។ ជាពិសេស ការបង្កើតឱ្យមានក្រុមការងារបច្ចេកទេសថ្នាក់ស្រុក បានបង្ហាញថា ការកិច្ចសហការក្នុងចំណោមអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ សហគមន៍នេសាទ ក្រុមកសិករ និងអង្គការសង្គមស៊ីវិល អាចញុាំងឱ្យការធ្វើសេចក្តីសម្រេចចិត្តជាផ្លូវមួយ និងមានភាពជាក់ស្តែងដែលអាចអនុវត្តបានកាន់តែប្រសើរ។ តាមរយៈការសម្របសម្រួលការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ការការពារជលផល ការធ្វើផែនការប្រើប្រាស់ដីធ្លី និងសកម្មភាពចិញ្ចឹមជីវិតនៅត្រឹមមូលដ្ឋាន វេទិកាពហុភាគីទាំងនេះ អាចជួយកាត់បន្ថយទំនាស់ធនធាន បង្កើនការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងធានាថា ការវិនិយោគបានឆ្លើយតបទៅតាមតម្រូវការជាក់ស្តែងរបស់សហគមន៍។ ការសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ក៏ធ្វើឱ្យការឆ្លើយតបប្រើរយៈពេលខ្លីជាងមុនក្នុងអំឡុងពេលមានទឹកជំនន់ និងគ្រោះរាំងស្ងួត និងលើកកម្ពស់ការប្រើប្រាស់ថវិកា និងធនធានបច្ចេកទេសដែលមានកំណត់ ឱ្យកាន់តែមានប្រសិទ្ធភាព។

អ្វីដែលសំខាន់នោះ ការចូលរួមយ៉ាងសកម្មរបស់ក្រុមងាយរងគ្រោះ រួមមាន ស្ត្រី កសិករខ្នាតតូច និងសហគមន៍នេសាទ អាចបង្កើនភាពស្របច្បាប់ គណនេយ្យភាព និងសមភាពក្នុងដំណើរការធ្វើផែនការ។ ការចូលរួមរបស់សហគមន៍ ជួយពង្រឹងភាពជាម្ចាស់ការ និងអនុលោមភាពតាមច្បាប់ដែលបានព្រមព្រៀងគ្នា ដែលអាចនាំទៅរកលទ្ធផលប្រកបដោយចីរភាពជាងមុន។ គំរូវិមជ្ឈការ និងដោយបរិយាបន្នទាំងនេះ ផ្តល់នូវវិធីសាស្ត្រដែលអាចពង្រីកគំរូអនុវត្តបាន និងចំណាយតិចដែលអាចយកទៅអនុវត្តបាននៅទូទាំងប្រទេស ដើម្បីពង្រឹងអភិបាលកិច្ចទឹកដែលមានភាពសមស្រប និងឆ្លើយតបទៅនឹងបញ្ហាបានតាមស្ថានភាពរបស់មូលដ្ឋាន។

### ៣.៨ កិច្ចសហប្រតិបត្តិការឆ្លងដែន

នៅប្រទេសកម្ពុជា សន្តិសុខទឹក ទទួលរងឥទ្ធិពលខ្លាំងមកពីការអភិវឌ្ឍនៅទន្លេមេគង្គលើ ដោយសារទំនប់ និងអាងស្តុកទឹក ប៉ះពាល់ដល់លំហូរទឹក កាត់បន្ថយដីល្បាប់ និងការផ្លាស់ប្តូរលំនាំទៅតាមរដូវ។ ដោយសារតែទឹកផ្ទៃដីភាគច្រើន មានប្រភពមកពីក្រៅប្រទេស ប្រតិបត្តិការវារីអគ្គិសនីបានប៉ះពាល់ដល់តំបន់ទឹកលិច កម្ពស់ទឹកនៅរដូវប្រាំង ផលិតភាពវិស័យនេសាទ និងសុខភាពប្រព័ន្ធអេកូឡូស៊ីនៃបឹងទន្លេសាប ដែលនាំឱ្យវិស័យកសិកម្ម ប្រឈមនឹងការខាតបង់ខ្លាំងឡើង និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានហានិភ័យកាន់តែខ្ពស់។

ដូច្នេះ កិច្ចសហប្រតិបត្តិការក្នុងតំបន់ គឺមានសារៈសំខាន់ណាស់។ ថ្វីដ្បិត កិច្ចព្រមព្រៀងគណៈកម្មការទន្លេមេគង្គឆ្នាំ១៩៩៥ ផ្តល់នូវក្របខ័ណ្ឌពិគ្រោះយោបល់ តម្រូវការចាំបាច់ផ្សេងទៀត រួមមាន ការមានតម្លាភាពកាន់តែខ្លាំង ការចែករំលែកទិន្នន័យជាក់ស្តែង ការព្យាករដែលប្រកបដោយការសម្របសម្រួល និងការធ្វើផែនការអាងទន្លេរួមគ្នា ដើម្បីគ្រប់គ្រងហានិភ័យរួម និងលើកកម្ពស់ការប្រើប្រាស់ទឹកប្រកបដោយសមធម៌ និងចីរភាព។

### ៣.៩ ហិរញ្ញប្បទានប្រកបដោយចីរភាព និងវិស័យឯកជន

ការផ្តល់ហិរញ្ញប្បទានដោយចីរភាព គឺមានសារៈសំខាន់សម្រាប់អភិបាលកិច្ចទឹកប្រកបដោយប្រសិទ្ធភាព ដោយធានាថា គោលនយោបាយអាចប្រែទៅជាហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដែលអាចទុកចិត្តបាន រួមមាន ប្រព័ន្ធធារាសាស្ត្រ វិធានការឆ្លើយតបទៅនឹងទឹកជំនន់ ទឹកស្អាត អនាម័យ និងការស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ។ ការវិនិយោគលើវិស័យទឹក នៅតែមិនទទួលបានហិរញ្ញប្បទានគ្រប់គ្រាន់ ដូច្នេះរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងការចូលរួមពីវិស័យឯកជន តាមរយៈភាពជាដៃគូរវាងរដ្ឋ និងឯកជន ព្រមទាំងគំនិតផ្តួចផ្តើមគ្រប់គ្រងផ្សេងៗ ត្រូវកៀរគរធនធានបន្ថែមលើថវិកាជាតិ និងប្រើប្រាស់ឱ្យមានប្រសិទ្ធភាព ជាពិសេសសម្រាប់តំបន់ដែលនៅខ្វះខាតសេវាកម្មទឹក។

## ៤. សេចក្តីសន្និដ្ឋាន

កិច្ចសន្ទនាគោលនយោបាយកម្រិតខ្ពស់ស្តីពី អភិបាលកិច្ចទឹកនៅកម្ពុជា បានបញ្ជាក់យ៉ាងច្បាស់ថា បញ្ហាប្រឈមនៃវិស័យទឹក

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
(៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
cdri@cdri.org.kh
http://www.cdri.org.kh

នៅប្រទេសកម្ពុជា គឺមានលក្ខណៈជារចនាសម្ព័ន្ធ មិនមែនជាបញ្ហារូបវន្តតែម៉្យាងនោះទេ។ ទោះបីជាកម្ពុជាទទួលបានអត្ថប្រយោជន៍ពីលំហូរទឹកតាមរដូវកាលពីទន្លេមេគង្គដ៏សន្ធឹកសន្ធាប់ ផលិតភាពនៃបឹងទន្លេសាប និងការពឹងផ្អែកកាន់តែខ្លាំងឡើងលើទឹកក្រោមដីក៏ដោយ ក៏ប្រភពធនធានទាំងនេះកាន់តែចុះខ្សោយ ដោយសារមានអភិបាលកិច្ចដែលមិនស៊ីសង្វាក់គ្នា ការសម្របសម្រួលមានភាពទន់ខ្សោយ និងការខូចខាតប្រព័ន្ធអេកូឡូស៊ី។ ការប្រែប្រួលអាកាសធាតុ លំហូរដែលគ្រប់គ្រងដោយវារីអគ្គិសនី ការធ្លាក់ចុះដីល្បាប់ ការបាត់បង់ទីជម្រក ការបូមទាញយកទឹកក្រោមដីច្រើនពេក និងវិសមភាពក្នុងការទទួលបានសេវាទឹកស្អាត និងអនាម័យទាំងនេះ កំពុងបង្កើនសម្ពាធលើប្រព័ន្ធចំណីអាហារ និងជីវភាពជនបទ។ កិច្ចសន្ទនាបានគូសបញ្ជាក់ថា បើគ្មានស្ថាប័នរឹងមាំ និងវិធីសាស្ត្រគ្រប់គ្រងទឹកបែបចម្រុះទេ ហានិភ័យដែលទាក់ទងគ្នាទាំងនេះ នឹងបន្តបង្កផលប៉ះពាល់ដល់ជលផល កសិកម្ម សុខភាពសាធារណៈ និងភាពធន់ផ្នែកសេដ្ឋកិច្ច ជាពិសេសសម្រាប់សហគមន៍ងាយរងគ្រោះដែលរស់នៅក្នុងតំបន់ទំនាបលិចទឹក និងតំបន់ដាច់ស្រយាល។

ព្រមជាមួយគ្នានេះ ប្រទេសកម្ពុជាមានឱកាសល្អសម្រាប់ធ្វើការកែលម្អ។ យន្តការវិមជ្ឈការដែលមានស្រាប់ ស្ថាប័នដែលមានមូលដ្ឋាននៅតាមសហគមន៍ស្រាប់ ក្រុមការងារអភិវឌ្ឍន៍ជនបទ និងវេទិកាសហប្រតិបត្តិការក្នុងតំបន់ អាចផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់អភិបាលកិច្ចកាន់តែមានការឆ្លើយតប និងប្រកបដោយបរិយាបន្ន។ ការពិភាក្សានេះបានបញ្ជាក់ថា ការធ្វើផែនការដោយផ្អែកលើភស្តុតាង ប្រព័ន្ធតាមដានរួមគ្នា ការការពារប្រព័ន្ធអេកូឡូស៊ី និងការកំណត់តួនាទី និងភារកិច្ចរបស់ស្ថាប័នឱ្យច្បាស់លាស់ អាចជួយបង្កើនប្រសិទ្ធភាព និងគណនេយ្យភាព។ ការផ្ទេរអំណាច និងធនធានទៅឱ្យអាជ្ញាធរខេត្ត និងស្រុក ការពង្រឹងការចូលរួមរបស់សហគមន៍ ជាពិសេសក្នុងចំណោមស្ត្រី និងក្រុមងាយរងគ្រោះ និងការពិចារណារួមបញ្ចូលវិស័យទឹកក្រោមដី និងសេវាទឹកស្អាត និងអនាម័យ ទៅក្នុងការធ្វើផែនការអាងទន្លេ នឹងអាចផ្តល់ដំណោះស្រាយដែលសមស្របទៅនឹងមូលដ្ឋានកាន់តែប្រសើរឡើង។ អ្វីដែលសំខាន់ដូចគ្នានេះដែរ គឺការពង្រឹងកិច្ចសហការឆ្លងដែនជាមួយប្រទេសក្នុងតំបន់ រួមមានការចែករំលែកទិន្នន័យដែលមានតម្លាភាព និងការគ្រប់គ្រងទន្លេដែលមានការសម្របសម្រួល សំដៅដោះស្រាយផលប៉ះពាល់ពីសកម្មភាពនៅទន្លេមេគង្គលើ និងកាត់បន្ថយភាពមិនប្រាកដប្រជានៅទូទាំងតំបន់ទន្លេមេគង្គ។

នៅទីបំផុត ការគ្រប់គ្រងធនធានទឹក មិនមែនត្រឹមតែជាការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តប៉ុណ្ណោះទេ ប៉ុន្តែជារបៀបដែលសេចក្តីសម្រេចត្រូវបានធ្វើឡើង នរណាខ្លះចូលរួម និងថាតើការអភិវឌ្ឍអាចការពារប្រព័ន្ធអេកូឡូស៊ី និងប្រជាពលរដ្ឋក្នុងរយៈពេលវែងបានដែរឬអត់។ ដោយមានការសម្របសម្រួលរវាងវិទ្យាសាស្ត្រ ស្ថាប័ន សហគមន៍ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ឱ្យស្របគ្នានឹងក្របខ័ណ្ឌគ្រប់គ្រងធនធានទឹកចម្រុះច្បាស់លាស់ កម្ពុជាអាចប្រែក្លាយភាពងាយរងគ្រោះជាប្រព័ន្ធទៅជាឱកាសដើម្បីកសាងភាពធន់ឱ្យកាន់តែប្រសើរឡើង។ បើមានកិច្ចសហការរួមគ្នា អនុវត្តការកែទម្រង់ដែលជាលទ្ធផលនៃកិច្ចសន្ទនា អាចជំរុញការផ្គត់ផ្គង់ទឹកដែលមានភាពជឿជាក់បាន ការនេសាទ និងកសិកម្មប្រកបដោយចីរភាព ហានិភ័យគ្រោះមហន្តរាយ ត្រូវបានកាត់បន្ថយ និងលទ្ធផលអភិវឌ្ឍន៍កាន់តែប្រកបដោយសមធម៌ បង្កើតបានជាមូលដ្ឋានគ្រឹះសម្រាប់អនាគតដែលមានសុវត្ថិភាពផ្នែកធនធានទឹក និងធន់នឹងអាកាសធាតុសម្រាប់មនុស្សជំនាន់ក្រោយបន្តទៀត៕

## ឯកសារយោង

វិទ្យាស្ថានCDRI នឹងមានចេញផ្សាយនាពេលខាងមុខ។ *អភិបាលកិច្ចទឹកនៅកម្ពុជា៖ លទ្ធផលនៃកិច្ចសន្ទនាគោលនយោបាយកម្រិតខ្ពស់ស្តីពីអភិបាលកិច្ចទឹក ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥*។ របាយការណ៍កិច្ចសន្ទនាគោលនយោបាយ។ ភ្នំពេញ៖ CDRI។

សុន្ទរកថាអបអរសាទររបស់ ឯកឧត្តម ដេរីក ឃីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥។

សុន្ទរកថាគន្លឹះរបស់ ឯកឧត្តមបណ្ឌិត អាន ពេជ្រ ហត្ថដា រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម នៅភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥។

សុន្ទរកថាបើកកិច្ចសន្ទនាគោលនយោបាយរបស់ ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម នៅភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥។

បទបង្ហាញរបស់វាគ្មិនមកពីក្រសួង និងដៃគូអភិវឌ្ឍន៍ផ្សេងៗ។

សុន្ទរកថាស្វាគមន៍របស់បណ្ឌិត អេង នេត្រា នាយិកាប្រតិបត្តិវិទ្យាស្ថានCDRI នៅភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥។